
Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org

## 4.12 ស្តេចសាឡូម៉ូនប្រើប្រាជ្ញារបស់គាត់

ឪពុករបស់សាឡូម៉ូន គឺស្តេចដាវីឌបានទទួលមរណភាព។ ឥឡូវនេះគឺជាការងាររបស់សាឡូម៉ូនដែលត្រូវធ្វើជាស្តេច។ គឺមានទំនួលខុសត្រូវច្រើនណាស់! ដាវីឌបានផ្តល់ការណែនាំជាច្រើនដល់សាឡូម៉ូន អំពីការស្តាប់តាមព្រះ។ ប៉ុន្តែ ឥឡូវនេះសាឡូម៉ូនបានគិតអំពីប្រជាជនទាំងអស់នៅក្នុងក្រុងហើយ តើនេះនឹងក្លាយជាការងារដ៏ធំមួយយ៉ាងណាទៅ។

ជនជាតិអ៊ីស្រាអែលចង់ថ្វាយបង្គំព្រះ តែពុំមានព្រះវិហារនោះទេ។ ការងារមួយដែលសាឡូម៉ូនត្រូវធ្វើ គឺសាងសង់ព្រះវិហារសម្រាប់ការថ្វាយបង្គំព្រះ។ ប្រជាជនមិនបានស្តាប់បង្គាប់ព្រះ ក្នុងការដែលពួកគេថ្វាយបង្គំឥឡូវនេះទេ។ សូម្បីតែសាឡូម៉ូន ក៏មិនបានស្តាប់បង្គាប់ដែរ ។

សាឡូម៉ូនត្រូវការប្រាជ្ញា មកពីព្រះ។ នៅយប់មួយ ព្រះទ្រង់បានមានបន្ទូលទៅកាន់សាឡូម៉ូនក្នុងសុបិន្ត។ ព្រះទ្រង់បានសួរសាឡូម៉ូននូវអ្វីដែលគាត់ចង់បានលើសអ្វីៗទាំងអស់។ សាឡូម៉ូនបាននិយាយថា គាត់ចង់បានប្រាជ្ញា។ គាត់ចង់មានសមត្ថភាពគ្រប់គ្រងប្រជាជនដោយប្រាជ្ញាវាងវៃ ដោយស្តាប់តាមព្រះ។ ព្រះក៏បានប្រទានប្រាជ្ញាដល់សាឡូម៉ូន។ ទ្រង់ក៏សព្វព្រះទ័យនូវអ្វីដែលលោកបានស្នើសុំនេះ។ នៅថ្ងៃមួយ សាឡូម៉ូនត្រូវប្រើប្រាជ្ញារបស់គាត់ តាមរបៀបដ៏អស្ចារ្យមួយ។ មានស្ត្រីពីរនាក់ដែលរស់នៅជាមួយគ្នាក្នុងផ្ទះតែមួយ។ ពួកគេមានជម្លោះដើម្បីត្រូវដោះស្រាយ ។ ពួកគេមកគាល់ព្រះបាទសាឡូម៉ូន ដើម្បីដោះស្រាយបញ្ហាដ៏ធំនេះ ។

ស្ត្រីម្នាក់បាននិយាយថា "ឱ! បរពិតព្រះអម្ចាស់អើយ! ខ្ញុំម្ចាស់និងស្ត្រីនេះបានរស់នៅក្នុងផ្ទះតែមួយ។ ខ្ញុំបានមានកូនមិនជាយូរប៉ុន្មានទេ។ បន្ទាប់មក មិនយូរប៉ុន្មានដែរ ស្ត្រីម្នាក់នេះក៏មានកូនដែរ។ នៅពេលនោះគ្មាននរណាម្នាក់នៅក្នុងផ្ទះជាមួយយើងទេ។ ទារករបស់ស្ត្រីម្នាក់នេះក៏បានស្លាប់នៅពេលយប់នោះ។ នាងបានក្រោកឡើងយកកូនពីខ្ញុំ ពេលដែលខ្ញុំកំពុងដេកលក់ ហើយបានដាក់កូនរបស់នាង ដែលបានស្លាប់នោះក្បែរខ្ញុំ។ ពេលដែលខ្ញុំក្រោកពីគេងពេលព្រឹក ខ្ញុំក៏បានឃើញទារកនៅក្បែរខ្ញុំ បានស្លាប់បាត់ទៅហើយ ។ នៅពេលខ្ញុំមើលទារកនោះ ដោយយកចិត្តទុកដាក់ ទើបខ្ញុំដឹងថា គឺមិនមែនជាកូនរបស់ខ្ញុំទេ! គឺនាងបានប្តូរវាហើយ!" ស្ត្រីម្នាក់ទៀតស្រែកថា"ទេ! ទារកដែលនៅរស់គឺជាកូនរបស់ខ្ញុំ! កូនរបស់អ្នកបានស្លាប់ទៅហើយ" ។

ស្ត្រីដែលនិយាយដំបូងទទូចថា «ទេ! ទារកដែលនៅរស់ទើបជារបស់ខ្ញុំ!" ស្តេចសាឡូម៉ូនមានរាជឱង្ការថា៖ «ក្នុងចំណោមអ្នករាល់គ្នាមានម្នាក់ពោលថា "ទារកដែលនៅរស់គឺជាកូនរបស់ខ្ញុំ ហើយកូនដែលស្លាប់នោះគឺជាកូនរបស់នាង" ។ ហើយម្នាក់ទៀតក្នុងចំណោមអ្នករាល់គ្នា បាននិយាយថា "នោះមិនមែនជាការពិតទេ!" បន្ទាប់មកស្តេចបានឲ្យគេយកដាវឲ្យទ្រង់មួយ ។ "ដូច្នេះ យើងនឹងកាត់កូនដែលនៅរស់នេះជាពីរចំណែក ដើម្បីចែកគ្នាម្នាក់ម្ខាង!" ។

ស្ត្រីដែលពិតជាស្រឡាញ់កូនរបស់នាងម្នាក់នោះ បាននិយាយថា" អូ! បរពិតព្រះអម្ចាស់អើយ! សូមឲ្យទារកនោះទៅនាងចុះ ដ្បិតវាត្រូវតែរស់!" ស្ត្រីម្នាក់ទៀតនិយាយថា កាត់វាចែកគ្នាទៅ! ស្តេចសាឡូម៉ូនបាន សម្រេចចិត្ត ហើយមានរាជឱង្ការថា៖ «ស្ត្រីដែលចង់ឲ្យទារកនោះនៅរស់ នាងគឺជាម្តាយពិតហើយ។ កុំសម្លាប់វាអី ។ ឱ្យទារកនោះទៅនាងទៅ។ ជនជាតិអ៊ីស្រាអែលទាំងអស់បានឮរឿងទាំងនេះហើយ ប្រជាជនបានអស្ចារ្យក្នុងចិត្តជាខ្លាំង ។ ពួកគេដឹងថាប្រាជ្ញារបស់សាឡូម៉ូន គឺមកពីព្រះ ។

**(១ពង្សាវតារក្សត្រ ៣)**

## 4.12 ស្តេចសាឡូម៉ូនប្រើប្រាជ្ញារបស់គាត់ សេចក្តីណែនាំសម្រាប់គ្រូបង្រៀន

**កំណត់សម្គាល់**:

សាឡូម៉ូនបានឡើងសោយរាជ្យលើសាសន៍អ៊ីស្រាអែល បន្ទាប់ពីឪពុករបស់គាត់ដាវីឌបានសោយទិវង្គតទៅ ។ ព្រះបានមានបន្ទូលទៅសាឡូម៉ូន ហើយបានសួរគាត់នូវអ្វី ដែលគាត់ចង់បានបំផុត។ សាឡូម៉ូនបានតបថា គាត់ចង់បានប្រាជ្ញា ដើម្បីដឹកនាំប្រជាជនទាំងអស់។ មានស្ត្រីពីរនាក់នៅក្នុងក្រុង ដែលរស់នៅក្នុងផ្ទះតែមួយជាមួយគ្នា ។ ពួកគេម្នាក់ៗមានកូនម្នាក់មួយ ។ នៅយប់មួយ ទារកម្នាក់បានស្លាប់។

ស្ត្រីម្នាក់បាននិយាយថា ទារករបស់នាងម្នាក់ទៀតបានស្លាប់ហើយ ហើយនាងបានប្តូរទារកស្លាប់របស់នាងជាមួយទារកដែលនៅរស់។ ស្ត្រីទី២បាននិយាយថា នេះមិនពិតទេ ។ ពួកគេបានទៅគាល់ស្តេចសាឡូម៉ូនដើម្បីដោះស្រាយជម្លោះរបស់គេ។ ស្តេចសាឡូម៉ូនមានរាជឱង្ការថា៖ «សូមយកដាវមួយមកឲ្យខ្ញុំ។ យើងនឹងកាត់ទារកចែកឲ្យពួកគេម្នាក់ពាក់កណ្តាល។ ស្ត្រីម្នាក់បាននិយាយថា "សូមឱ្យទារកនោះទៅនាងចុះ។ ដ្បិតវាត្រូវតែរស់" ។

ស្ត្រីម្នាក់ទៀតបាននិយាយថា កាត់កូនចែកគ្នាទៅ! ស្តេចសាឡូម៉ូនបានធ្វើការសម្រេចចិត្តថា ស្ត្រីដែលចង់ឱ្យទារកនោះនៅរស់ គឺជាម្តាយពិតហើយ។ ដូច្នេះក៏បានឱ្យទារកនោះទៅនាង។ ប្រជាជនអ៊ីស្រាអែលទាំងអស់ ពេលបានឮរឿងទាំងនេះហើយពួកគេមានការអស្ចារ្យក្នុងចិត្តជាខ្លាំងចំពោះប្រាជ្ញារបស់ស្តេចសាឡូម៉ូន។ ពួកគេបានដឹងថា វាគឺមកពីព្រះ ។

**សំណួរ:**

1) តើសាឡូម៉ូនចង់បានអ្វីជាងគេពីព្រះ?
2) តើស្ត្រីទាំងពីរនាក់នោះមានបញ្ហាអ្វី?
3) តើស្តេចសាឡូម៉ូនបាននិយាយថា ទ្រង់គួរតែធ្វើអ្វី?
4) តើស្តេចសាឡូម៉ូនសំរេចថា ស្ត្រីណាជាម្តាយពិតប្រាកដ?
5) តើប្រាជ្ញារបស់ស្តេចសាឡូម៉ូនបានមកពីណា?

**ចម្លើយ:**

1) សាឡូម៉ូនចង់បានប្រាជ្ញាជាងគេ ។
2) ស្ត្រីទាំងពីរនាក់មានកូនម្នាក់មួយ ។ ទារកម្នាក់បានស្លាប់ ហើយស្ត្រីទាំងពីរនាក់បាននិយាយថា ទារកដែលនៅរស់គឺជារបស់ពួកគេ។
3) ស្តេចសាឡូម៉ូនបាននិយាយថា ទ្រង់គួរតែកាត់ទារកចែកជាពីរចំណែក ។
4) ស្តេចសាឡូម៉ូនបានដឹងថា ស្ត្រីម្នាក់ដែលចង់ឲ្យទារកនៅរស់នោះ គឺជាម្តាយពិតហើយ ។
5) ប្រាជ្ញារបស់ស្តេចសាឡូម៉ូន គឺមកពីព្រះអម្ចាស់។


Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org